D119538 DC-Cam

**នេះគឺជាបទសំភាសន៍ជាមួយលោកតា រ៉េស ទត**
**អ្នកភូមិកោះផល ឃុំប៉ើស ១ ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម**
**ដោយ : កុសល្យ សូរិយា តារា ឧស្មាន**
**នៅថ្ងៃទី ១៣-១១-១៩៩៩**

ស- តាឈ្មោះអ្វីដែរ ?
ឆ- រ៉េស ទត ។
ស- អាយុប៉ុន្មាន ?
ឆ- ៦៧ ឆ្នាំ ។
ស- ជំនាន់ខ្មែរក្រហមតានៅទីនេះដែរឬទេ ?
ឆ- នៅ ។
ស- បានឃើញរឿងហេតុអ្វីខ្លះកើតឡើងនៅទីនេះ ?
ឆ- ពេលនោះគេហៅទៅប្រជុំ ប្រជុំកាលនោះដំបូងបំផុតហើយ ប្រជុំនៅប៉ើស នៅក្នុងអង្គប្រជុំគេនិយាយថា គេអោយពួកយើងទាំងអស់ប្រមូលគម្ពីរកូរអាន ។
ស- នៅឆ្នាំណា ?
ឆ- ប្រហែលជា ១៩៧៤ ។ មើលទៅពួកខ្ញុំមួយភូមិនេះអត់តាមគេ អញ្ចឹងពួកខ្មែរក្រហមវាមករុះស្វ៉ាវអស់ពីរ ។
ស- ពួកខ្មែរក្រហមបាននៅទីនេះដែរ ?
ឆ- អត់ទេ វានៅកន្លែងផ្សេង វាមករុះចោល ។
ស- ពួកនោះមកពីណាដែរ ?
ឆ- មកពីក្រូចឆ្មារ និងមកពីប៉ើស ។
ស- មានបងប្អូនខ្មែរឥស្លាមគេប្រើអោយមកជួយដកហូតគម្ពីរកូរអានដែរឬទេ ?
ឆ- អត់ទេ សុទ្ធតែខ្មែរក្រហមមកពីស្រុកគេតែម្តង ។
ស- មុនពេលគេប្រមូលគម្ពីរកូរអាននោះ គេប្រាប់ថាយ៉ាងម៉េចខ្លះ ?
ឆ- ពេលប្រមូលអត់បានគេមករុះស្វ៊ាវ ។
ស- មានបងប្អូនអ៊ុំប៉ុន្មាននាក់ដែលពួកខ្មែរក្រហមយកទៅសំលាប់ ?
ឆ- អស់ទៅហើយ នៅសល់តែ៤នាក់ទេ ។
ស- អស់ប៉ុន្មាន ?
ឆ- អស់ច្រើនណាស់ ជាង១០នាក់ទៅហើយបើរាប់ទៅ ។
ស- តើគេចាប់យកពីផ្ទះតែម្តងឬ ?
ឆ- បាទ គេចាប់ពីផ្ទះ ចាប់ទាំងខ្ញុំទៀតផង ។
ស- តើអ៊ុំគេចាប់យកទៅដាក់នៅឯណា ?
ឆ- គេយកទៅដាក់គុកនៅក្រូចឆ្មារ រយៈពេល ៦ ខែ ១០ ថ្ងៃ ។

ស- ពីឆ្នាំណាដល់ឆ្នាំណា ?

ឆ- ពី ១៩៧៤-៧៥ ។

ស- នៅក្រូចឆ្មារនេះ ឮថាកាលពីឆ្នាំ ១៩៧៥ មានជនជាតិចាមបះបោរ ពេលនោះអ៊ុំនៅក្នុងមន្ទីរឃុំឃាំង ?

ឆ- អត់ទេ មកវិញហើយ ។ រឿងបះបោរនោះក៏មកពីវាហ្នឹងដែរ វាហៅយើងទៅប្រជុំ វាថាថ្ងៃ ១២-៩-១៩៧៥ វាមកប្រជុំនៅភូមិនេះ ។ ដល់ពេលវាមក វាអោយខ្ញុំហៅមនុស្សទាំងអស់ក្នុងភូមិចូលទៅប្រជុំ ព្រោះវាមកនោះសុទ្ធតែមេៗតែម្តង ។

ស- មេនោះឈ្មោះអ្វី ?

ឆ- គណៈស្រុកក្រូចឆ្មារនេះ ឈ្មោះតាផា តាប៊ុនដាអនុ បន្ទាប់តាយោក គាត់នេះចាមដែលបានខ្មែរក្រហម ផ្ទះគាត់នៅជំនីក បន្ទាប់មកទៀតតាយោកដែរ ផ្ទះគាត់នៅភូមិទ្រា ។ ពេលប្រជុំគេយកតុដាក់ចំមាត់ទ្វារអញ្ចេះ ។

ស- ពេលគេហៅទៅប្រជុំ បងប្អូនជនជាតិចាមទៅមួយភូមិតែម្តងឬ ?

ឆ- អត់ទេ ទៅតែខ្ញុំនេះទេ ។ ហើយគេផ្ញើរសំបុត្រមកអោយខ្ញុំថា ថ្ងៃ១២ ខែ ៩ អោយប្រមូលកំលាំងចូលវិហារ គេមកប្រជុំ ដល់ថ្ងៃនោះគេមកមែន ។

ស- ហើយអ៊ុំទៅជួបគេទេ ?

ឆ- ទៅឯណាបើគេមកទីនេះហើយ ។

ស- ខ្មែរក្រហមនិយាយថាអោយដកកូរអានទាំងអស់ពីបងប្អូនចាមឬ ?

ឆ- ទេ គេមិនទាន់និយាយទេ គ្រាន់តែគេហៅទាំងអស់គ្នាអោយចូលវិហារ នៅម៉ោង ២ ថ្ងៃ ១២-៩-៧៥ ។

ស- ហេតុអ្វីបានជាគេដកគម្ពីរកូរអានពីជនជាតិចាម ?

ឆ- ខ្ញុំអត់ដឹងដែរ ។ ពេលប្រជុំនោះ មានយោធាគេ ២០ នាក់ នៅគ្រប់បង្គួច ។

ស- មេខ្មែរក្រហមដែលដឹកនាំការប្រជុំនោះ អ៊ុំមានចាំឈ្មោះទេ ?

ឆ- មកប្រជុំនោះ គឺតាផាជាចៅហ្វាយស្រុក ។

ស- គេនិយាយថាយ៉ាងម៉េច ?

ឆ- ផែនការគេមកប្រជុំមានពីរយ៉ាង ។ ទីមួយ ដោយគេយកខ្មែរមកជាមួយនេះ គេចង់ហូតតាៗនៅក្នុងភូមិ ៤០ នាក់ យកទៅរៀនសូត្រ ឬយកទៅធ្វើបាបអីយ៉ាងម៉េច ខ្ញុំអត់ដឹងទេ ។ ទីពីរ អង្គការដាក់ផែនការអោយប្រជាជនក្នុងភូមិនេះគោរពតាម ៥ខ ។ ខទី១ ស្ត្រីចាមត្រូវកាត់សក់អោយខ្លី រួចរៀបការជាមួយខ្មែរ ។ ខទី២ អោយប្រមូលគីតាប កូរអាន ។ ខទី៣ អោយចិញ្ចឹមជ្រូក ។ ពេលនោះ មានក្មេងតូចម្នាក់ ចូលមកតុនោះ វាមកទះមាត់តែម្តង ក្មេងនោះអាយុប្រហែល ៦ ឆ្នាំ អត់មានអ្នកណាប្រើវាទេ ។ ក្មេងនោះក៏មកទះមាត់តាផា រួចតានោះក៏ឈប់និយាយ ហើយគាត់ថា យីសអាក្មេង នេះកាចណាស់វ៉ឺ វាធំបន្តិចធ្វើយោធាបាំតែម្តង ។ ខទី៤ អោយយើងលែងសំពះយ៉ាង ។ ខទី៥ អោយយើងលែងបួស ។

ស- ក្រៅពីអ៊ុំ មានអ្នកណាទៀតទេដែលបានចូលរួមប្រជុំ ?

ឆ- នេះ តានេះអីហ្នឹង ។

ស- មានអ្នកណាផ្សេងទៀតទេ ?

ឆ- អូរ ពួកនេះសុទ្ធតែក្មេងៗទេ ។ ខ្ញុំមិនដែលនិយាយទេ លោកណាដែលមកប៉ុន្មានដង ខ្ញុំមិនដែលនិយាយប្រាប់ទេ ។

ស- បន្ទាប់ពីប្រជុំហើយ បងប្អូនចាមធ្វើតាមខទាំង៥នោះ ឬក៏យ៉ាងណា ?

ឆ- អត់ទេ ។

ស- មានជំទាស់អ្វីទេ ?

ឆ- អត់ជំទាស់អ្វីទេ នៅស្ងៀមតែម្តង ។ នៅថ្ងៃទី១៣ គេមកចាប់ គេចាប់ឈ្មោះ សុះ ស្មាន ជាអ្នកភូមិនេះ គេចាប់ពេលដែលចេញពីភូមិទៅទាញគោ គេយកទៅមួយយប់ រួចគេបាញ់ម្នាក់ទៀតឈ្មោះ ម៉ាត់ ស្លេះ ។

ស- អ៊ុំឃើញផ្ទាល់នឹងភ្នែកទេ ?

ឆ- ឃើញ ព្រោះនៅក្នុងភូមិនេះហើយ ។ ឈ្មោះ ស្មានដែលគេយកទៅនោះ បានមួយយប់គេលែងមកវិញ រួចគេអោយស្មាននោះនិយាយប្រាប់អ្នកភូមិថា កោះផលនេះគេកំទេចចោល ។

ស- ឈ្មោះ ស្មាននេះ នៅរស់ទេ ?

ឆ- ស្លាប់អស់ហើយ ។

ស- កំទេចមានន័យថាយ៉ាងម៉េច ?

ឆ- កំទេចនោះ គឺគេធ្វើអោយអស់ អោយទៅជាផេះ ។

ស- បន្ទាប់ពីនោះទៀត .........?

ឆ- បើអញ្ចឹងនិយាយពីក្មេងៗក្នុងភូមិនេះ នាំគ្នាធ្វើបាតុកម្ម គ្មានអ្នកណាប្រើវាទេ វាធ្វើបាតុកម្មខ្លួនឯង ។

ស- ពួកខ្មែរក្រហមអោយកាត់សក់ មានកាត់សក់ទេ ?

ឆ- អត់ទេ ។

ស- អញ្ចឹងពួកខ្មែរក្រហមធ្វើយ៉ាងម៉េចខ្លះ ?

ឆ- វាខឹង វាផ្តាំមកថាចង់កំទេចភូមិនេះចោល ។ ចាប់ពីនោះទៅ ក្មេងៗវាចេះតែនាំគ្នាធ្វើបាតុកម្ម វាស្រែកថាបាត់សាសនាហើយ ក្មេងៗវានាំគ្នាស្រែកទាំងហ្វូងៗ រយៈពេលបីថ្ងៃ ។

ស- ពួកខ្មែរក្រហមមានធ្វើសកម្មភាពអ្វីខ្លះនៅពេលក្មេងៗកំពុងស្រែកនោះ ?

ឆ- អត់ទេ អត់មានអ្នកណាចូលមកទេ នៅតែពួកយើងហ្នឹង ។ បន្ទាប់មកទៀតវាស្រែកថា តស៊ូសាសនាកុំអោយបាត់ នាំគ្នាស្រែកទាំងហ្វូងៗ ទាំងភូមិតែម្តង រយៈពេលបីថ្ងៃ ។ បន្ទាប់មកទៀតវាស្រែកថា ស្លាប់ដើម្បីសាសនា ។

ស- ស្រែកពីថ្ងៃណាដល់ថ្ងៃណា ?

ឆ- មកទល់ថ្ងៃ ១៩-៩-១៩៧៥ ។

ស- ហេតុអ្វីបានជាអ៊ុំចាំថ្ងៃខែច្បាស់ម្លេះ ?

ឆ- ថីមិនចាំ បើខ្ញុំនៅធ្វើការនោះ ។ អាពតវាអោយខ្ញុំធ្វើប្រធានភូមិ កាលជំនាន់នោះ ?

ស- ហើយខាងផ្នែកសាសនាមានធ្វើអ្វីដែរ ?

ឆ- ជាភូឈ្មួយហាកិម ។

ស- អ៊ុំ ទទួលបញ្ជាពីអ្នកណាខ្លះពេលដែលលោកអ៊ុំធ្វើជាប្រធានភូមិនោះ ?

ឆ- ពួកស្រុកហ្នឹង ដូចជាតាផា ។

ស- តាផានោះធ្លាប់ប្រាប់អ៊ុំអោយធ្វើអ្វីខ្លះ ?

ឆ- វាអោយប្រមូលគីតាប កូរអាន វាមិនអោយសំយ៉ាង ប៉ុន្តែប្រជាជនក្នុងភូមិអត់មានធ្វើតាមវាទេ ។

ស- ពេលដែលគេប្រើអោយអ៊ុំប្រមូលគីតាប កូរអាននោះ តើអ៊ុំមានធ្វើតាមគេទេ ?

ឆ- អត់ទេ ។

ស- ហេតុអ្វីបានជាអ៊ុំប្រាប់អ្នកនៅក្នុងភូមិអោយប្រមូល ?

ឆ- ចេះតែប្រាប់អោយតែរួចៗទៅ ។ តាមពិត ខ្ញុំមិនអាចធ្វើតាមគេបានទេ ធ្វើឯណាបើសាសនាយើងបានគម្ពីរនោះហើយ បើវាយកគម្ពីរទៅដុតចោល យើងមានសាសនាឯណាទៀត ។

ស- ក្រៅពីបញ្ជាអោយអ៊ុំដកគម្ពីរកូរអាននោះ តើគេមានប្រើអោយយើងធ្វើអ្វីផ្សេងទៀតទេ ?

ឆ- អត់ទេ គ្រាន់តែមកប្រជុំតែប៉ុណ្ណឹង ។

ស- អ៊ុំធ្វើជាប្រធានភូមិពីឆ្នាំណាដល់ឆ្នាំណា ?

ឆ- ពី ១៩៧៣-៧៥ ។ នៅថ្ងៃទី ២២-៩ វាយកកាំភ្លើងធំមកដាក់បួនទិស ជ្រុងខាងកើតចំងាយពីផ្ទះនេះប្រហែល ៥០០ ម៉ែត្រ ។

ស- ហេតុអ្វីបានជាអ៊ុំដឹង ?

ឆ- ថីមិនដឹងព្រោះខ្ញុំឃើញ ។ ដាក់នៅខាងលិចចុងព្រៃកមួយកន្លែង ដាក់នៅលើកោះខាងភូមិសោយមួយកន្លែង ។

ស- តាផាមានប្រាប់អ៊ុំថាហេតុអ្វីគេដាក់កាំភ្លើងនោះទេ ?

ឆ- ទេ គេមិនប្រាប់ខ្ញុំទេ ព្រោះគេខឹងនឹងខ្ញុំហើយ ។

ស- អញ្ចឹងបានន័យថាចាប់ថ្ងៃទី ២២ ខែ ៩ អ៊ុំលែងមានទំនាក់ទំនងជាមួយតាផាហើយ ?

ឆ- អត់ទេ ដល់ពេលគេប្រជុំរួចផុតតែម្តង គេអត់មករវល់នឹងយើងទេ ។

ស- ក្រោយពីគេដាក់កាំភ្លើងធំនោះហើយ គេមានធ្វើអ្វីទៀតទេ ?

ឆ- ថ្ងៃ ២៤ ខែ ៩ វាបាញ់ហើយ ពួកកាំភ្លើងអត់មានទំនេរមួយនាទីទេ ពេលដែលវាបាញ់និយាយគ្នាក្នុងភូមិនេះអត់ពួទេ ប៉ុន្តែអត់មានធ្លាក់ក្នុងភូមិទេ បើធ្លាក់ហួសទៅកណ្តាលទន្លេ បើផ្ទះនៅលើមេឃ ។ ពេលវាផ្លោងដាក់ ៣ ថ្ងៃ មានទ័ពមកសងខាង មកពីខាងកើត និងមកពីខាងលិច អញ្ចឹងវាបាញ់អ្នកនៅទប់ទល់ជាមួយវាហ្នឹង ។

ស- អ៊ុំមានស្គាល់ទេ ទ័ពនោះគេយកពីខាងណាមក ?

ឆ- មិនដឹងជាយកពីខាងណាមកទេ ។

ស- ហើយអ្នកភូមិនេះស្លាប់ច្រើនទេ ?

ឆ- រយៈពេល ៣-៤ ថ្ងៃ គ្រាន់តែស្លាប់យកមកកប់ទីនេះ ៤៦ នាក់ ។

ស- ហេតុអ្វីបានជាអ៊ុំដឹង ?

ឆ- ថីមិនដឹង យើងនាំគ្នាសែងមក ។

ស- យកមកកប់ក្នុងរណ្តៅនោះឬ ?

ឆ- អត់ទេ កាលនោះមិនទាន់មានរណ្តៅនោះទេ ប៉ុន្តែនៅខាងក្រោយកមមកមិនបានមិនដឹងជាប៉ុន្មានទេ យកម៉េចបាន បើទ័ពវានៅទីនោះហើយ ។

ស- មានតទល់អីជាមួយគេទេ ?

ឆ- មានអីតទល់ បើមានតែកាំបិត ផ្គាក់ ។

ស- ៤៦ នាក់នោះ មានខ្មែរទេ ?
ឆ- ទេ សុទ្ធតែចាមទាំងអស់ ។ គ្រាន់តែអញ្ជើង ៧យប់ ៧ ថ្ងៃ ។
ស- ពេលនោះអ៊ុំនៅទីនេះទេ ?
ឆ- នៅទីនេះ ។ បន្ទាប់មកគេជំលៀស ។
ស- អ៊ុំមានកូនចៅប៉ុន្មាននាក់កាលពីជំនាន់ខ្មែរក្រហម ?
ឆ- ៧ នាក់ ។
ស- បន្ទាប់មកគេជំលៀសទៅខាងណាខ្លះ ?
ឆ- មិនដឹងជាទៅណាខ្លះទេ ទៅតែពីសតែពាស អត់មាននៅក្នុងភូមិនេះម្នាក់ទេ ។
ស- នៅឆ្នាំណា ?
ឆ- ១៩៧៥ ។
ស- ដល់ពេលត្រឡប់មកភូមិវិញ ភូមិខ្ញុំមុនបាតុកម្មមានមនុស្ស ១ ៨៦៤ នាក់ ពេលមកដល់កន្លែងដើមវិញអស់ ឃើញ ១៨៣ នាក់ ។
ស-ស្ថិតិដែលធ្វើនោះមាននៅសល់ទេ ?
ឆ- អត់មានស្ថិតិទេ មករាប់គ្នាតែម្តង ។
ស- បន្ទាប់ពីបាតុកម្មទៅ មានសល់ប្រជាជនទីនេះ គេជំលៀសដែរឬទេ ?
ឆ- អត់មានទេ ។
ស- ជំលៀសទៅកន្លែងណាខ្លះ ?
ឆ- ទៅតែពីសតែពាសហ្នឹង ។
ស- ពេលអ៊ុំទៅ ទៅរស់នៅសហករណ៍ខ្មែរ តើពួកខ្មែរក្រហមបានធ្វើអ្វីខ្លះ ?
ឆ- ខ្ញុំនេះរត់ទៅឆ្ងាយណាស់ រត់ចូលទៅវៀតណាម ខ្ញុំអត់មានដឹងអីទេនៅស្រុកខ្មែរនេះ ។